**សេចក្ដីសិក្សា៖** ម៉ូឌុលនេះមានរយៈពេលប្រហែល ២ ម៉ោង ដើម្បីសិក្សា។

# ម៉ូឌុល ៣៖ សិទ្ធិប្រហាក់ប្រហែល

## គោលបំណង

បន្ទាប់ពីបញ្ចប់ការសិក្សាម៉ូឌុលនេះអ្នកគួរតែអាច

១. រាយជាបញ្ជីគុណប្រយោជន៍អំពីសិទ្ធិប្រហាក់ប្រហែល។

២. ដកស្រង់រយៈពេលការពារសិទ្ធិប្រហាក់ប្រហែលដូចដែលមានចែកក្នុងអនុសញ្ញាទីក្រុងរ៉ូម និងកិច្ចព្រមព្រៀង TRIPS។

៣. ពន្យល់ប្រហែល ២៥០ ពាក្យ ពីរបៀបស្ដីពីទស្សនៈទាននៃសិទ្ធិប្រហាក់ប្រហែលមានភាពពាក់ព័ន្ធ "ប្រពៃណីនិងទំនៀមទំលាប់អ្នកស្រុក"។

© WIPO/OMPI

## អារម្ភកថា

សិទ្ធិប្រហាក់ប្រហែលគឺជាសិទ្ធិក្នុងទិដ្ឋភាពមួយចំនួនប្រហាក់ប្រហែលទៅនឹងសិទ្ធិអ្នកនិពន្ធ។ គោលបំណងនៃសិទ្ធិប្រហាក់ប្រហែលគឺការពារផលប្រយោជន៍ស្របច្បាប់របស់រូបវន្តបុគ្គល និងនីតិបុគ្គលដែលចូលរួមបង្កើតស្នាដៃសម្រាប់សាធារណជន។ ឧទាហរណ៍ជាក់ស្តែងមួយគឺអ្នកចម្រៀង ឬអ្នកភ្លេងដែលសម្តែងស្នាដៃរបស់អ្នកនិពន្ធបទភ្លេងដល់សាធារណៈជន។ គោលបំណងទាំងមូលនៃសិទ្ធិប្រហាក់ប្រហែលទាំងនេះគឺការពារមនុស្សនិងអង្គភាពទាំងនោះដែលបញ្ចូលទាំងខ្លឹមសារការច្នៃប្រឌិត បច្ចេកទេស ឬអង្គភាពជំនាញ ក្នុងដំណើរនៃការនាំមកនូវស្នាដៃមួយដល់សាធាណៈជន។

ម៉ូឌុលនេះនឹងពន្យល់អ្នកអំពីប្រភេទសិទ្ធិប្រហាក់ប្រហែល តើសិទ្ធិទាំងនោះត្រូវទទួលបានយ៉ាងដូចម្តេច រយៈពេលនៃសិទ្ធិដែលទទួលបាន និងសន្ធិសញ្ញាអន្តរជាតិចំបងៗ ឬអនុសញ្ញាអន្តរជាតិចំបងៗ ដែលពាក់ព័ន្ធជាមួយនឹងសិទ្ធិប្រហាក់ប្រហែល។

© WIPO/OMPI

# សិទ្ធិប្រហាក់ប្រហែល

អ្វីដែលនិយាយដំបូងគឺសិទ្ធិប្រហាក់ប្រហែលនោះគឺជាពាក្យថ្មីមួយ ហើយឯកសារមួយចំនួនសំដៅដល់សិទ្ធិដូចគ្នានឹងពាក្យសិទ្ធិជិតខាង (neighboring rights) ។ ម៉ូឌុលនេះនឹងប្រើប្រាស់ត្រឹមតែពាក្យសិទ្ធិប្រហាក់ប្រហែល។ ចាប់ផ្តើមការសិក្សារបស់អ្នកដោយធ្វើការស្តាប់វគ្គសម្លេងនៃសិទ្ធិប្រហាក់ប្រហែល។

វគ្គសម្លេងទី១៖ តើអ្នកអាចកំណត់ទស្សនៈទានសិទ្ធិប្រហាក់ប្រហែលនេះសម្រាប់ខ្ញុំម្តងទៀតទេ?

សិទ្ធិប្រហាក់ប្រហែលគឺមិនមែនជាសិទ្ធិអ្នកនិពន្ធទេ ប៉ុន្តែសិទ្ធិនេះគឺមានទំនាក់ទំនងគ្នាគ្នាយ៉ាងជិតស្និតជាមួយសិទ្ធិអ្នកនិពន្ធ សិទ្ធិទាំងនេះបានមកពីស្នាដៃដែលបានការពារដោយសិទ្ធិអ្នកនិពន្ធ។ ដូច្នេះសិទ្ធិទាំងនោះគឺតែងតែមានការពាក់ព័ន្ធគ្នា។ ផ្តល់នូវប្រភេទសិទ្ធិផ្តាច់មុខដូចគ្នានឹងសិទ្ធិអ្នកនិពន្ធ ប៉ន្តែសិទ្ធិប្រហាក់ប្រហែលមិនគ្របដណ្តប់លើស្នាដៃពិតនោះទេ។ សិទ្ធិប្រហាក់ប្រហែលគ្របដណ្តប់លើអ្វីដែលជាប់ទាក់ទងនឹងស្នាដៃមួយ ក្នុងន័យទូទៅក្នុងការនាំយកស្នាដៃទៅដល់សាធារណៈជន។ ឧទាហរណ៍ចម្រៀងដែលបានការពារដោយសិទ្ធិអ្នកនិពន្ធ ហើយវាឆ្លងកាត់ដំណាក់កាលផ្សេងៗ។

សន្មតថាយើងមានបទចម្រៀងដើមមួយបទ ជាធម្មតាវាត្រូវបានការពារសម្រាប់អ្នកនិពន្ធបទភ្លេង និងអ្នកនិពន្ធទំនុកជាអ្នកកាន់កាប់សិទ្ធិអ្នកនិពន្ធដើម ពួកគេនឹងផ្តល់វាទៅឲ្យអ្នកចម្រៀងម្នាក់ដែលសម្តែងវា និងគាត់ឬនាងនឹងត្រូវការនូវប្រភេទនៃការការពារមួយផងដែរ។ ប្រសិនបើវាត្រូវបានថតទុក ឬប្រសិនបើអ្នកចៀងសង្ឃឹមវាបានផ្សាយ អំពើទាំងនោះពាក់ព័ន្ធនឹងជម្រុញឲ្យក្រុមហ៊ុនដ៏ទៃ ដែលនឹងចង់បានត្រូវបានការពារមុនវាចូលដល់កិច្ចព្រមព្រៀងមួយ។ ដំបូងនៃសិទ្ធិប្រហាក់ប្រហែលទាំងនេះ ដែលកាលនោះគឺជាសិទ្ធិរបស់អ្នកសម្តែងស្នាដៃ ពោលគឺអ្នកសម្តែង អ្នកចម្រៀង តួសម្តែងនាដការ អ្នករបាំ អ្នកភ្លេង និងផ្សេងៗទៀត។

ពេលនោះមានក្រុមទី២មួយក្រុម ផលិតករហ្វូណូក្រាម ឬផលិតករពិតប្រាកដជាច្រើននៃបទចម្រៀងថតទុកជាសម្ភារៈថតទុក ខណៈដែលសម្ភារៈថតទុកចាប់ផ្តើមពីប្លាស្ទិកហ្វូណូក្រាមថតទុកក្នុងស៊ីឌី និងឧបករណ៍ថតទុកឌីជីថល។ ដែលទាំងនោះគឺជាការការពារប្រភេទ

© WIPO/OMPI

ពាណិជ្ជកម្មជាច្រើន ក្នុងន័យមួយដែលការបង្កើតគុណភាពការថតទុកសម្លេងមានច្រើនក្នុងការផលិតជាមួយនឹងកិច្ចការពារការវិនិយោគ បន្ទាប់ជាមួយនឹងការជាប់ទាក់ទងនឹងសិល្បៈដែលបានទាក់ទិនក្នុងការផលិត ការនិពន្ធ ឬការសម្តែងបទចម្រៀងមួយបទ។ យ៉ាងណាក៏ដោយសូម្បីតែក្នុងដំណើរការទាំងមូលនៃការជ្រើសរើសការជ្រោមជ្រែងដោយឧបករណ៍ អ្នកចេះចាំច្រើន ការរៀបចំ បទភ្លេង និងអ្វីផ្សេងៗទៀត មានវត្ថុធាតុប្រកបដោយភាពឆ្នៃប្រឌិតមួយចំនួនថែមទាំងភាពជាក់ស្តែងជាច្រើន និងវត្ថុធាតុពាណិជ្ជម្មដ៏សំខាន់។ យើងគួតែអត់ធ្មត់ក្នុងចិត្តដែលផលិតករទាំងនេះគឺជាក្នុងចំណោមជនរងគ្រោះភ្លាមជាច្រើន នៃការលួយបន្លំស្នាដៃ ខណៈដែលពួកគេមិនទទួលបាននូវប្រាក់កម្រៃ ដែលត្រូវបានបង្វែរទៅឲ្យផលិតករដែលលួចបន្លំស្នាដៃ ប៉ុន្តែជាធម្មតាការបាត់បង់របស់ពួកគេ ការបាត់បង់ហិរញ្ញវត្ថុរបស់ពួកគេគឺត្រូវបានធ្លាក់ចុះជាបន្តបន្ទាប់ចំពោះអ្នកសម្តែង និងអ្នកនិពន្ធ។ នេះគឺជាហេតុដែលផលិតករថតទុកសម្លេងត្រូវបានផ្តល់នូវសិទ្ធិជាក់លាក់ផងដែរ។

ក្រុមទីបីដែលទទួលបាននូវកិច្ចការពារនូវសិទ្ធិប្រហាក់ប្រហែលគឺអង្គភាពទូរផ្សាយ។ សិទ្ធិរបស់ពួកគេបានមកពីការឆ្នៃប្រឌិតរបស់ពួកគេ ពោលគឺការបង្កើតការផ្សព្វផ្សាយ មិនមែនកើតចេញពីមាតិកានៃការផ្សព្វផ្សាយ មិនចេញពីខ្សែភាពយន្ត ប៉ុន្តែចេញពីសកម្មភាពនៃការផ្សព្វផ្សាយ។ ការពិតណាស់ដែលពួកគេមានលទ្ធភាពបញ្ចេញសញ្ញាដែលបង្កើតបានជាការផ្សព្វផ្សាយដែលត្រូវផ្តល់ជូនពួកគាត់នូវកិច្ចការពារសិទ្ធិចំពោះសញ្ញាណទាំងនោះ។ ហើយក្រៅពីនេះ វាជាការវិនិយោគ ការខំប្រឹងដែលពួកគាត់បានបង្កើតក្នុងការដាក់បញ្ចូលគ្នា និងការផ្សព្វផ្សាយកម្មវិធីផ្សេងៗដែលបានពាក់ព័ន្ធ។

© WIPO/OMPI

វាគិ្មនបានបញ្ជាក់ផងដែរថា ការចាប់ផ្តើមដំបូងបំផុតនៃសិទ្ធិប្រហាក់ប្រហែលមិនដូចទៅនឹងសិទ្ធិអ្នកនិពន្ធនោះទេ ប៉ុន្តែពួកវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគ្នា "សិទ្ធិទាំងនេះ កើតចេញពីពីស្នាដៃមួយដែលបានការពារដោយសិទ្ធិអ្នកនិពន្ធ"។

ពេលខ្លះសិទ្ធិប្រហាក់ប្រហែលមានការពាក់ព័ន្ធនឹងស្នាដៃជាច្រើនដែលមិនត្រូវបានការពារដោយសិទ្ធិអ្នកនិពន្ធ ឧទាហរណ៍ ស្នាដៃដែលស្ថិតក្នុងកម្មសិទ្ធិសាធារណជន។ អនុញ្ញាត្តិឲ្យយើងពិចារណា សម្រាប់ជាឧទាហរណ៍ ព្យាណូមួយ concerto លេងភ្លេងដោយលោក បីតូវិន។ វាប្រហែលត្រូវបានសម្តែងក្នុងសាលប្រគុំតន្ត្រី ឬវាអាចត្រូវបានថតចម្លងទុកក្នុងស៊ីឌី។ លោកបីតូវិនបានស្លាប់ក្នុងឆ្នាំ១៨២៧ គ្រប់ស្នាដៃរបស់គាត់គឺជាកម្មសិទ្ធិរបស់សាធាណៈ ហើយដូច្នេះមិនធ្វើកិច្ចការពារសិទ្ធិអ្នកនិពន្ធនោះទេ។ ហេតុនេះ អ្នកណាម្នាក់មានសិទ្ធិសម្តែងនូវបទភ្លេងជា អាចនិយាយបានថាអ្នកណាម្នាក់ លេងភ្លេងព្យាណូរបស់លោកបិតូវិន ឬថតចម្លងក្នុងស៊ីឌី មិនចាំបាច់មានការអនុញ្ញាតនោះឡើយ។

យ៉ាងណាក៏ដោយក្នុងឧទាហរណ៍ដូចគ្នា អ្នកសម្តែងការប្រគុំតន្ត្រី (អ្នកលេងព្យាណូ និងវង់ភ្លេង) ដូចគ្នានឹងផលិតករនៃស៊ីឌីផ្ទុកការថតចម្លងការប្រគុំដន្ត្រីក៏ទទួលនូវសិទ្ធិប្រហាក់ប្រហែលដែរ ចំពោះការសម្តែងនៃការប្រគុំតន្ត្រី និងការថតចម្លងរបស់ពួកគាត់ដោយរៀងៗខ្លួន។ ហេតុដូច្នេះ ក្នុងឧទាហរណ៍ក្រោមនេះ ការពិចារណា មិនមានអ្នកណាម្នាក់មានសិទ្ធិទទួលថតចម្លងការសម្តែងផ្ទាល់នៃការប្រគុំដន្ត្រីដូចគ្នា ដោយគ្មានការយល់ព្រមពីអ្នកសម្តែងនោះទេ។ ដូចគ្នានេះគ្មានអ្នកណាម្នាក់គឺមានសិទ្ធិចម្លងនូវការថតចម្លងសម្លេងនៃការសម្តែងការប្រគុំដន្ត្រីព្យាណូដូចគ្នា ដោយគ្មានការយល់ព្រមពីផលិតករថតចម្លងសម្លេងនោះទេ។

វាប្រហែលមានកំពុងមានការចាប់អារម្មណ៍ កត់សម្គាល់ផងដែរថាផលិតករការថតចម្លងសម្លេងអាចទទួលនូវកិច្ចការពារ សូម្បីតែអ្វីៗដែលបានថតចម្លងគឺមិនត្រូវបានចាត់ទុកជាស្នាដៃក៏ដោយ។ ការថតចម្លងសម្លេងមួយប្រហែលជាផ្ទុកនូវសម្លេងធម្មជាតិ ដូចជា សម្លេងសត្វស្លាប រលកមហាសមុទ្រ។ល។ សម្លេងទាំងនោះគឺមិនមែនជាស្នាដៃនោះទេ។ យ៉ាងណាក៏ដោយ ក្រុមហ៊ុនថតចម្លងសម្លេងដែលបានរៀបផលិតកម្មស៊ីឌីផ្ទុកសម្លេងទាំងនោះនឹងបានការពារជំទាស់នឹងអំពើនៃការបន្លំផ្សេងទាក់ទងនឹងការថតចម្លងដូចគ្នា។

© WIPO/OMPI

## សំណួរវាយតម្លៃខ្លួនឯង

SQA ១. តើក្រុម ឬអង្គភាពទាំងបី ដែលទទួលបានសិទ្ធិប្រហាក់ប្រហែល មានអ្វីខ្លះ?
សរសេរចម្លើយរបស់អ្នកទីនេះ

| |
|---|
| |

ចុចទីនេះសម្រាប់ចម្លើយ

© WIPO/OMPI

SQA ចម្លើយទី ១

ក្រុមទាំងបីដែលទទួលបានសិទ្ធិរួមមាន

- អ្នកសម្តែង ដូចជា អ្នកចម្រៀង
- ផលិតករការថតចម្លង ដូចជាក្រុមហ៊ុនថតចម្លង
- អង្គភាពទូរផ្សាយ

វាគ្មិនបានបញ្ជាក់ថាជាកាលកំណត់និយមន័យការបន្លំក្នុងវគ្គសម្លេង។ ប្រសិនបើអ្នកមិនច្បាស់នូវអត្ថន័យនៃពាក្យនេះឥឡូវនឹងគឺជាពេលល្អមួយរកមើលក្នុងសន្ទានុក្រម។

© WIPO/OMPI

ដូចវគ្គសម្លេងដែលបានពន្យល់ សិទ្ធិប្រហាក់ប្រហែលជាទូទៅត្រូវបានផ្តល់ឱ្យអ្នកទទួលផលបីប្រភេទដូចជា អ្នកសម្តែង ផលិតករថតចម្លង និងអង្គភាពទូរផ្សាយ។

សិទ្ធិអ្នកសម្តែងគឺត្រូវបានស្គាល់ ពីព្រោះការបង្កើតប្រកបដោយការច្នៃប្រឌិតរបស់ពួកគេគឺចាំបាច់ផ្តល់នូវជីវិត ឧទាហរណ៍ ស្នាដៃភ្លេង ស្នាដៃវិនាដកម្ម និងស្នាដៃរាំរបាំ និងរូបភាពមានចលនា និងពីព្រោះតែពួកគេមាន ផលប្រយោជន៍ត្រឹមត្រូវក្នុងកិច្ចការពារស្របច្បាប់នៃការអធិប្បាយផ្ទាល់ខ្លួន។



សិទ្ធិផលិតករថតចម្លងគឺបានស្គាល់ ពីព្រោះ ធនធានប្រកបដោយការច្នៃប្រឌិត ធនធានហិរញ្ញវត្ថុ និងធនធានអង្គភាពរបស់ពួកគេគឺចាំបាច់បង្កើតការថតចម្លងសម្លេង ដែលប្រើប្រាស់ឲ្យជាប្រយោជន៍ចំពោះសាធារណជនក្នុងជាទំរង់ជំនួយហ្វូណូក្រាម (ថេប កាសែត ស៊ីឌី មីនីឌីស។ល។)។

ពួកគេក៏មាននូវផលប្រយោជន៍ពេញច្បាប់ផងដែរក្នុងការមានធនធានស្របច្បាប់ចាំបាច់ដើម្បីធ្វើសកម្មភាពជំទាស់នឹងការប្រើប្រាស់ដោយពុំមានការអនុញ្ញាត ទោះជាវាគឺជាគំនិតនៃការបង្កើត និងការចូលរួមចម្លងដោយមិនមានការអនុញ្ញាត(បន្លំ) ឬក្នុងរូបរាងជាការផ្សព្វផ្សាយដោយមិនមានការអនុញ្ញាត ឬការទំនាក់ទំនងដោយមិនមានការអនុញ្ញាតដល់សាធារណជនចំពោះហ្វូណូក្រាមរបស់ពួកគេក៏ដោយ។

ដូចគ្នាដែរ សិទ្ធិអង្គភាពទូរផ្សាយគឺត្រូវបានស្គាល់ពីព្រោះតែមុខងាររបស់ពួកគេស្ថិតក្នុងការបង្កើតស្នាដៃដែលប្រើប្រាស់ឲ្យជាប្រយោជន៍ចំពោះសាធារណជន និង នៃផលប្រយោជន៍ដោយត្រឹមត្រូវក្នុងការពិនិត្យលើការចាក់ផ្សាយ ឬការចាក់ផ្សាយឡើងវិញអំពីការផ្សព្វផ្សាយរបស់ពួកគេ។

© WIPO/OMPI

ឥឡូវស្ដាប់សម្លេងវគ្គបន្ទាប់ ដែលទាក់ទងទៅនឹងសារៈសំខាន់ និងការវិវត្តន៍សិទ្ធិប្រហាក់ប្រហែលចំពោះការផ្សព្វផ្សាយ ដោយផ្ដល់នូវឧទាហរណ៍តាមរយៈការផ្សព្វផ្សាយព្រឹត្តិការណ៍កីឡាមួយ។

វគ្គសម្លេងទី២ សិទ្ធិប្រហាក់ប្រហែលសម្រាប់អ្នកផ្សព្វផ្សាយនៃព្រឹត្តិការណ៍កីឡា

សិទ្ធិអ្នកផ្សព្វផ្សាយមានសារៈសំខាន់ជាពិសេសខ្លាំងណាស់ដែរក្នុងការទំនាក់ទំនងចំពោះ កម្មវិធីកីឡា។ ប្រទេសជាច្រើន កម្មវិធីកីឡាមួយនឹងមិនត្រូវបានពិចារណាថាមានសិទ្ធិក្នុង កិច្ចការពារសិទ្ធិអ្នកនិពន្ធនោះទេ។ មានប្រទេសមួយចំនួន ហើយប្រទេសអាមេរិកគឺជា ឧទាហរណ៍ដំបូង ដែលគិតថាការប្រកួតបាល់ទាត់មួយ ដែលនៅពេលដែលវាគឺត្រូវបាន ថតជាស្នាដៃសោតទស្សន៍ ពីព្រោះវាត្រូវបានពិចារណាថាគឺជាស្នាដៃប្រកបដោយការច្នៃប្រឌិតយ៉ាងគ្រប់គ្រាន់។ ប៉ុន្តែក្នុងប្រទេសដទៃទៀតជាច្រើនដែលច្បាប់កំណត់ថាល្បែងគឺ ជាកត្តាសម្រេចចិត្ត និងមិនប្រកបដោយការច្នៃប្រឌិតនូវចំណុចដែលមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់កិច្ចការពារទេ។ អ្នកថតរូបគឺគ្រាន់តែថតសកម្មភាព និងព្រឹត្តិការណ៍ដទៃទៀតតែប៉ុណ្ណោះ។ គាត់ប្រហែលជាអ្នកជំនាញខាងថតរូបម្នាក់ ប៉ុន្តែមិនមែនជាសិល្បករម្នាក់នោះទេ។ មានការផ្សព្វផ្សាយបែបនេះតិចតួចណាស់ ហេតុដូច្នេះ ប្រសិនបើមាន ការផ្សព្វផ្សាយទាំងនេះត្រូវបានពិចារណាអំពីតម្លៃនៃកិច្ចការពារ។

មានផលប្រយោជន៍យ៉ាងច្រើន លើ សិទ្ធិផ្សព្វផ្សាយតាមទូរស្សន៍សម្រាប់កីឡាអូឡាំពិក ។ អាចមានការដោះដូរលុយរាប់លាន ឬកោដ ដុល្លា ដោន អ៊ឺរ៉ូ ប្រាង់ ឬយេន ។

ប៉ុន្តែវាអាចជាការវិនិយោគដោយគ្មានការទាក់ទាញ ហើយវាអាចមិនមែន ប្រសិនបើអ្នក ផ្សព្វផ្សាយទាំងនោះ បានចំណាយលុយប្រចាំឆ្នាំសរុបយ៉ាងច្រើនជាមុនសម្រាប់អាជ្ញាប័ណ្ណផ្ដាច់មុខលើការផ្សព្វផ្សាយ ឬសម្រាប់មធ្យោបាយផ្ដាច់មុខនូវ ព្រឹត្តិការណ៍កីឡាសំខាន់ដ៏ទៃទៀតសម្រាប់ផលប្រយោជន៍នៃ តំបន់ផ្សព្វផ្សាយជាក់លាក់មួយ ហើយមិនអាចទទួលបានកិច្ចការពារដែលបានផ្ដល់ឱ្យដោយសិទ្ធិប្រហាក់ប្រហែលដើម្បីរារាំង ក្រុមហ៊ុនដ៏ទៃផ្សេងទៀតពីការផ្សព្វផ្សាយឡើងវិញស្នាដៃរបស់ពួកគេ ឬថតចម្លង និងលក់វីដេអូនៃស្នាដៃនោះ។




© WIPO/OMPI

ឧទាហរណ៍សង្ខេបនេះគឺមានបំណងពន្យល់អំពីមូលហេតុដែលក្រុមដែលពាក់ព័ន្ធដូចជាអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ មានសិទ្ធិទទួលបានកិច្ចការពារពីសិទ្ធិប្រហាក់ប្រហែល។

© WIPO/OMPI

ការឆ្លើយតបជាលក្ខណៈអន្តរជាតិដែលបានរៀបចំជាលើកដំបូងចំពោះតម្រូវការសម្រាប់កិច្ចការពារស្របច្បាប់នូវប្រភេទទាំងបីនៃផលប្រយោជន៍សិទ្ធិប្រហាក់ប្រហែលគឺជាសេចក្តីសន្និដ្ឋាន ក្នុងឆ្នាំ១៩៦១ នៃអនុសញ្ញាទីក្រុងរ៉ុម ឬជាពិសេស “អនុញ្ញាអន្តរជាតិស្តីពីកិច្ចការពារអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ។ មិនដូច” អនុសញ្ញាអន្តរជាតិជាច្រើនផ្សេងទៀត ដែលជាប្រភពនៃច្បាប់ជាតិ ហើយមានបំណងធ្វើសំយោគច្បាប់ដែលមានស្រាប់ អនុសញ្ញាទីក្រុងរ៉ុមគឺជាការខិតប្រឹងប្រែងបង្កើតបទបញ្ញាអន្តរជាតិមួយក្នុងវិស័យថ្មីមួយដែលច្បាប់ជាតិតិចតួចណាស់ដែលមានស្រាប់ក្នុងពេលនោះ។ នេះមានន័យថាប្រទេសជាច្រើននឹងមានពង្រាង និងអនុម័តច្បាប់មុនចូលជាសមាជិកអនុសញ្ញា។

ចាប់តាំងពីការអនុម័តអនុសញ្ញាឆ្នាំ ១៩៦១ ចំនួនប្រទេសជាច្រើនបានធ្វើច្បាប់ទាក់ទងទៅនឹងអនុសញ្ញា និងច្បាប់របស់ប្រទេសផ្សេងៗជាច្រើន ចែងលើសពីកម្រិតអប្បរមានក្នុងកិច្ចការពារដែលបានបង្កើតដោយអនុញ្ញា។

ការឆ្លើយតមជាលក្ខណៈអន្តរជាតិបច្ចុប្បន្នជាច្រើន ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃតម្រូវការកិច្ចការពារស្របច្បាប់ទាំងនេះ ជាដើមហេតុនាំឱ្យមានការចុះហត្ថលេខារបស់សន្ធិសញ្ញា WIPO ស្តីអំពីការសម្តែង និងហ្វូណូក្រាម (“WPPT”) ដែលបានបញ្ចប់នៅទីក្រុងហ្សឺណែវ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៦។ ការអភិវឌ្ឍនៃសន្ធិសញ្ញានេះគឺបានរៀបចំផ្តល់ជូននូវកិច្ចការពារឲ្យបានច្រើននូវសិទ្ធិបេតិកភ័ណ្ឌ និងសិទ្ធិសីលធម៌របស់អ្នកសម្តែង និងផលិតករហ្វូណូក្រាម ជាពិសេសចំពោះការទាញយកផលប្រយោជន៍របស់ពួកគេក្នុងទម្រង់ឌីជីថល រួមទាំងលើប្រព័ន្ធអ៊ីនធឺណែត។ សន្ធិសញ្ញនេះចូលជាធរមាននៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២។

ឥឡូវអ្នកយល់អំពីប្រភេទមនុស្ស និងអង្គភាពដែលអាចទទួលបានកិច្ចការពារក្រោមសិទ្ធិប្រហាក់ប្រហែល អ្វីបន្ទាប់សម្រាប់ការពិចារណាគឺ “តើសិទ្ធិទាំងនោះមានអ្វីខ្លះ:” ជាគោលការណ៍សិទ្ធិទាំងនោះគឺស្រដៀងទៅនឹងសិទ្ធិដែលផ្តល់ឱ្យម្ចាស់សិទ្ធិអ្នកនិពន្ធ។ នោះគឺជាសិទ្ធិរារាំងអ្នកដ៏ទៃពីការទាញយកផលប្រយោជន៍ដោយគ្មានការអនុញ្ញាតពីការសម្តែង ថតចម្លង ឬផ្សព្វផ្សាយដែលបានការពារ។

© WIPO/OMPI

## សិទ្ធិបានផ្តល់ឲ្យអ្នកទទួលផលពីសិទ្ធិប្រហាក់ប្រហែល

សិទ្ធិបានផ្តល់ជូនអ្នកទទួលផលបីពីសិទ្ធិប្រហាក់ប្រហែលក្នុងច្បាប់ជាតិគឺដូចតទៅ ទោះបីជាមិនមែនសិទ្ធិទាំងអស់ត្រូវបានផ្តល់ឲ្យក្នុងច្បាប់តែមួយក៏ដោយ។

- អ្នកសម្តែងគឺត្រូវបានផ្តល់ឲ្យនូវសិទ្ធិជាច្រើនរាំងនឹងការកម្រិត(ការថតចម្លង) ការផ្សព្វផ្សាយ និងការទាក់ទងដល់សាធារណជនអំពីការសម្តែងផ្ទាល់របស់ពួកគេ ដោយគ្មានការយល់ព្រមពីពួកគេ និងសិទ្ធិរាំងការកម្រិតផលិតឡើងវិញអំពីការសម្តែងរបស់ពួកគេ។ សិទ្ធិក្នុងការផ្សព្វផ្សាយ និងសិទ្ធិផ្សព្វផ្សាយជាសាធាណនៃការថតបញ្ចូលក្នុងហ្វូណូក្រាមជាលក្ខណៈពាណិជ្ជកម្ម អាចជាប្រភេទនៃលាភការប្រកបដោយសមធម៌ ជាជាងសិទ្ធិរាំង។ នេះអាចតាមរយៈ អាជ្ញាប័ណ្ណផ្តាច់មុខដែលបានពិភាក្សាក្នុងម៉ូឌុលសិទ្ធិអ្នកនិពន្ធ។ ដោយលក្ខណៈនៃ ការច្នៃប្រឌិត ច្បាប់ជាតិមួយចំនួនក៏ផ្តល់សិទ្ធិសីលធម៌ឱ្យអ្នកសម្តែងផងដែរ ដែលអាចប្រឆាំងនឹងការលុបចោលដោយមិនសមហេតុផលនូវឈ្មោះរបស់ពួកគេ ឬការកែប្រែការសម្តែងដែលប៉ះពាល់ដល់ពួកគេ។
- ផលិតករហ្វូណូក្រាមគឺត្រូវបានផ្តល់ឲ្យនូវសិទ្ធិអនុញ្ញាត្ត ឬហាមឃាត់ផ្ទាល់ និងមិនផ្ទាល់ក្នុងការផលិតឡើងវិញ ការនាំចូល និងការចែកចាយហ្វូណូក្រាមរបស់ពួកគេ និងថតចម្លងវត្ថុទាំងនោះ និងសិទ្ធិទទួលបានលាភការប្រកបដោយសីលធម៌ សម្រាប់ការផ្សព្វផ្សាយ និងទំនាក់ទំនងដល់សាធារណៈជនអំពីហ្វូណូក្រាម។

អង្គភាពផ្សព្វផ្សាយគឺត្រូវបានផ្តល់នូវសិទ្ធិអនុញ្ញា ឬហាមឃាត់ការផ្សព្វផ្សាយឡើងវិញ ការកម្រិត និងការផលិតឡើងវិញនូវការផ្សព្វផ្សាយរបស់ពួកគេ។ ក្នុងច្បាប់ខ្លះសិទ្ធិបន្ថែមគឺត្រូវបានផ្តល់ឲ្យ ឧទាហរណ៍ ក្នុងប្រទេសនៃសហភាពអ៊ឺរ៉ុប ផលិតករហ្វូណូក្រាម និងអ្នកសម្តែងគឺត្រូវបានផ្តល់ឲ្យនូវសិទ្ធិជួលហ្វូណូក្រាម (ចំពោះអ្នកសម្តែង ស្នាដៃសោទស្សន៍) និងប្រទេសខ្លះផ្តល់ឲ្យសិទ្ធិជាក់លាក់លើការផ្សព្វផ្សាយតាមខ្សែ។ ក្នុងកិច្ចព្រមព្រៀង TRIPSផលិតករហ្វូណូក្រាម (ក៏ដូចជាម្ចាស់សិទ្ធិដ៏ទៃផ្សេងទៀតក្នុងច្បាប់ជាតិស្តីពីហ្វូណូក្រាម) គឺត្រូវបានផ្តល់ឲ្យសិទ្ធិជួល។

ដូចជាករណីក្នុងច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ អនុសញ្ញាទីក្រុងរ៉ុម និងច្បាប់ជាតិមានការដាក់កំហិតយ៉ាងពិតប្រាកដចំពោះការអនុញ្ញាតសិទ្ធិ ជាឧទាហរណ៍ ការប្រើប្រាស់ឯកជន ប្រើចំពោះការដកស្រង់ខ្លីៗក្នុងការទាក់ទងជាមួយការរាយការណ៍ពីព្រឹត្តិការណ៍បច្ចុប្បន្ន និងប្រើសម្រាប់ការបង្រៀន ឬការស្រាវជ្រាវវិទ្យាសាស្ត្រ ពីកិច្ចការពារការសម្តែង ហ្វូណូក្រាម និងការផ្សព្វផ្សា

© WIPO/OMPI

យ។ ប្រទេសជាច្រើនអនុញ្ញាត្តតាមប្រតិបត្តិការដាក់កហិតប្រភេទដូចគ្នាក្នុងសិទ្ធិប្រហាក់ប្រហែលដូចជាច្បាប់របស់ពួកគេដែលផ្តល់ទំនាក់ទំនងក្នុងកិច្ចការពារសិទ្ធិអ្នកនិពន្ធ។ រយៈពេលការពារសិទ្ធិប្រហាក់ប្រហែលក្រោមអនុសញ្ញាទីក្រុងរ៉ូមគឺមានរយៈពេល ២០ ឆ្នាំគិតចាប់ពីដំណាច់ឆ្នាំនៃ៖

ការសម្តែងកើតឡើង ដោយការសម្តែងមិនបញ្ចូលក្នុងហ្វូណូក្រាម

ការកម្រិត(កាថតចម្លង) ករណីបានថតបញ្ចូលក្នុងហ្វូណូក្រាមនូវការសម្តែង អ្នកគួរតែកំណត់ថាច្បាប់ជាតិជាច្រើន ដែលការពារសិទ្ធិប្រហាក់ប្រហែល ផ្តល់ឲ្យរយៈពេលវែងជាងរយៈពេលខ្លីបំផុតដែលមានចែងក្នុងអនុសញ្ញាទីក្រុងរ៉ូម។

ក្នុងកិច្ចព្រមព្រៀងTRIPS សិទ្ធិអ្នកសម្តែង និងផលិតករហ្វូណូក្រាមគឺត្រូវបានការពារសម្រាប់រយៈពេល ៥០ ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំនៃការថតបញ្ចូល ឬការសម្តែង និងស្ថិទ្ធិអង្គភាពផ្សព្វផ្សាយសម្រាប់រយៈពេល ២០ឆ្នាំគិតចាប់ពីដំណាច់ឆ្នាំនៃការផ្សព្វផ្សាយបានកើតឡើង។ ដូច្នេះមានន័យថាប្រទេសដែលចូលជាសមាជិកទៅនឹងកិច្ចព្រមព្រៀងTRIPS នឹងបានផ្តល់ឬកែប្រែច្បាប់របស់ពួកគេ ផ្តល់កិច្ចការពារវែងជាងដូចដែលបានតម្រូវដោយអនុសញ្ញាទីក្រុងរ៉ូម។

ក្នុងល័ក្ខខ័ណ្ឌការអនុវត្តសិទ្ធិ មធ្យាបាយដោះស្រាយសម្រាប់ការរំលោភបំពាន ឬការប្រព្រឹត្តបទល្មើសសិទ្ធិប្រហាក់ប្រហែលគឺ ប្រហាក់ប្រហែលទៅនឹងម្ចាស់ដែលមានសិទ្ធិអ្នកនិពន្ធទាំងនោះ។នេះរួមមានការអភិរក្ស ឬវិធានការបណ្តោះអាសន្ន ដំណោះស្រាយរដ្ឋប្បវេណីទោសព្រហ្មទណ្ឌ វិធានការតាមមាត់ច្រកព្រំដែន និងវិធានការ មធ្យោបាយការដោះស្រាយនិងទណ្ឌកម្មប្រឆាំងនឹងការរំលោភក្នុងទិដ្ឋភាពឧបករណ៍បច្ចេកទេស។ សូមរំលឹកឡើងវិញសម្ភារៈដែលបានបង្ហាញក្នុងម៉ូឌុលសិទ្ធិអ្នកនិពន្ធមុន។

គំនិតសិទ្ធិប្រហាក់ប្រហែលបានទាក់ទាញការប្រុងប្រយ័ត្នជាមធ្យោបាយនៃកិច្ចការពារការបង្ហាញពីវប្បធម៌ដែលមិនបានថតចម្លងនៃប្រទេសកំពុងអភិវឌ្ឍនជាច្រើន ដែលគឺជាផ្នែកនៃប្រពៃណីទំនាមទំម្លាប់។ ដោយសារមានអន្តរាគមន៍របស់អ្នកសម្តែងទើបការបង្ហាញប្រពៃណីទំនាមទំម្លាប់ទាំងនោះគឺត្រូវបានផ្សព្វផ្សាយជាសាធារណ។ ដោយការផ្តល់ជូននូវកិច្ចការពារសិទ្ធិប្រហាក់ប្រហែល ប្រទេសកំពុងអភិវឌ្ឍអាចផ្តល់ជូនផងដែរនូវកិច្ចការពារដ៏ទូលំទូលាយ ដល់ការសម្តែងវប្បធម៌ បុរាណ ដែលមានតម្លៃ ដែលកំណត់ពីអត្តិភាពនិងអត្តសញ្ញាណ ដែលពិតជាមានសារៈសំខាន់ដែលអាចបែងចែកវប្បធម៌នីមួយៗបានពីប្រទេសមួយទៅប្រទេសមួយ ឬទូទាំងពិភពលោក។

© WIPO/OMPI

ដូចគ្នាផងដែរ កិច្ចការពារផលិតករហ្វូល្វាក្រោម និងអង្គភាពទូរផ្សាយផ្សាយ ជួយបង្កើតជាមូលដ្ឋានសម្រាប់លទ្ធភាពឧស្សាហកម្មជាតិផ្សព្វផ្សាយការបង្ហាញវប្បធម៌ជាតិក្នុងប្រទេស និងជាសំខាន់ ក្នុងទីផ្សាយក្រៅប្រទេស។ ចរន្តប្រជាប្រិយភាពដ៏សម្បើមនៃ "តន្ត្រីពិភពលោក" បង្ហាញថាមានទីផ្សារបែបនេះ ប៉ុន្តែមិនមែនផលប្រយោជន៍សេដ្ឋកិច្ចដែលបានពីការធ្វើអាជីវកម្មនៃទីផ្សារទាំងនេអ បានត្រឡប់ទៅប្រទេសដែលជាប្រភពដើមនៃការបង្ហាញវប្បធម៌នោះទេ។

ជាសង្ខេបកិច្ចការពារសិទ្ធិប្រហាក់ប្រហែលមានគោលបំណងពីរ គឺការបង្ការវប្បធម៌ជាតិ និងផ្តល់ជាមធ្យោបាយសម្រាប់ការធ្វើអាជីវកម្មក្នុងទីផ្សាយអន្តរជាតិ។

© WIPO/OMPI

## សង្ខេប

ក្នុងផ្នែកនេះ អ្នកបានសិក្សាអំពីសិទ្ធិប្រហាក់ប្រហែល ហើយក៏អាចហៅបានផងដែរថា សិទ្ធិពាក់ព័ន្ធ ឬជាពិសេស “សិទ្ធិពាក់ព័ន្ធនឹងសិទ្ធិអ្នកនិពន្ធ”។ គោលបំណងរបស់សិទ្ធិប្រហាក់ប្រហែលគឺការពារផលប្រយោជន៍ស្របច្បាប់របស់មនុស្សពិតប្រាកដ ឬអង្គភាពដែលចូលរួមបង្កើតស្នាដៃជូនសាធារណជន ឬអ្នកទាំងនោះដែលបានបន្ថែមការច្នៃប្រឌិត បច្ចេកទេស ឬអង្គភាពជំនាញ។

ជាទំលាប់សិទ្ធិបប្រាក់ប្រហែលបានផ្តល់ទៅឲ្យអ្នកទទួលផលប្រយោជន៍បីប្រភេទដូចជា អ្នកសម្តែង ផលិតករ និងអ្នកផ្សព្វផ្សាយ។ តម្រូវការកិច្ចការពារស្របច្បាប់នៃអ្នកទទួលផលប្រយោជន៍ទាំងបីក្រុមនេះគឺត្រូវបានកំណត់ក្នុងអនុសញ្ញាទីក្រុងរ៉ុមឆ្នាំ១៩៦១ ដែលជាការខិតខំប្រឹងប្រែងបង្កើតបទបញ្ញាអន្តរជាតិក្នុងវិស័យថ្មីមួយដែលក្នុងច្បាប់ជាតិមួយចំនួនមានរួចទៅហើយ។ ជាងនេះទៅទៀត ប្រទេសជាច្រើនជាធម្មតាបានេះព្រៀងង និងអនុម័តច្បាប់មុនចូលជាសមាជិកអនុសញ្ញានេះ។ អនុសញ្ញាទីក្រុងរ៉ុម ទោះជាមិនពេញបរិបូណ៌ និងក្នុងតម្រូវការបន្ថែមបន្ថយ គឺនៅតែជាគំរូអន្តរជាតិមួយគត់សម្រាប់កិច្ចការពារក្នុងវិស័យនេះ។ ដូចជាសិទ្ធិអ្នកនិពន្ធ អនុសញ្ញាទីក្រុងរ៉ុម និងច្បាប់ជាតិមានដាក់កំហិតលើការអនុញ្ញាតសិទ្ធិសម្រាប់ការប្រើប្រាស់ឯកជន ការប្រើប្រាស់ដកស្រង់ខ្លី និងការប្រើប្រាស់សម្រាប់ការបង្រៀន ឬការស្រាវជ្រាវវិទ្យាសាស្ត្រ។

រយៈពេលនៃកិច្ចការពារសិទ្ធិប្រហាក់ប្រហែល ដូចដែលបានប្រកាសក្នុងអនុសញ្ញាទីក្រុងរ៉ុម គឺមានរយៈពេល ២០ ឆ្នាំគិតចាប់ពីដំណាច់ឆ្នាំនៃ (១) ការថតចម្លងបានបង្កើត (២) ការសម្តែងបានកើតឡើង (៣) ការផ្សព្វផ្សាយបានកើតឡើង។ ការអភិរក្ស ឬវិធានការណ៍បណ្តោះអាសន្នសំដៅចំពោះមធ្យោបាយដោះស្រាយសម្រាប់ការរំលោភបំពាន ឬការប្រព្រឹត្តល្មើសលើសិទ្ធិប្រហាក់ប្រហែល។ ទាំងនេះរួមទាំងមធ្យោបាយដោះស្រាយរដ្ឋប្បវេណី ទោសព្រហ្មទណ្ឌ វិធានការណ៍តាមមាត់ច្រកព្រំដែន និងវិធានការណ៍ មធ្យោបាយដោះស្រាយ និងទណ្ឌកម្មប្រឆាំងនឹងរំលោភក្នុងទិដ្ឋភាពឧបករណ៍បច្ចេកទេស។

សន្ធិសញ្ញាថ្មីបំផុតក្នុងវិស័យសិទ្ធិប្រហាក់ប្រហែល សន្ធិសញ្ញា WIPO ស្តីពីការសម្តែង និងហ្វូណូក្រាម (“WPPT”) បានបង្កើនវិសាលភាពអំពីកិច្ចការពារសិទ្ធិអ្នកសម្តែង និងផលិករហ្វូណូក្រាមដោយបង្កើនដល់ “សម័យឌីជីថល” ជាមួយកិច្ចការពារដែលបានកំណត់ចំពោះការធ្វើអាជីវកម្មលើស្នាដៃដែលបានការពារក្នុងទំរង់ឌីជីថល រួមទាំងលើអ៊ីនធឺណែត។

© WIPO/OMPI

វាគឺមានសារៈសំខាន់កំណត់ថាសិទ្ធិប្រហាក់ប្រហែលអាចនឹងត្រូវបានប្រើប្រាស់ផង ដែលសម្រាប់ការពារការបង្ហាញពីវប្បធម៌ដែលមិនបាននិពន្ធ និងមិនបានថតចម្លងក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន។ កិច្ចការពារសិទ្ធិប្រហាក់ប្រហែលបានក្លាយជាផ្នែកមួយដ៏ធំនិងជាបុរេលក្ខខ័ណ្ឌចាំបាច់ដល់ការចូលរួមក្នុងប្រព័ន្ធពាណិជ្ជកម្ម និងការវិនិយោគអន្តរជាតិ។

អត្ថបទច្បាប់

អនុសញ្ញាទីក្រុងរ៉ូមសម្រាប់កិច្ចការពារអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ

កិច្ចព្រមព្រៀងTRIPS

សន្ធិសញ្ញា WIPO ស្តីពីការសម្តែង និងហ្វូណូក្រាម (WPPT)

អនុសញ្ញាទីក្រុងព្រុចសែល ស្តីពីការចែកចាយកម្មវិធីបញ្ជូនរលកសញ្ញាតាមផ្កាយរណប។

© WIPO/OMPI